# គ្រូពេទ្យ

តើអ្នកមានចំណាប់អារម្មណ៍ក្នុងការផ្តល់សេវាថែទាំសុខភាព នៅតាមសហគមន៍ដែរឬទេ? តើអ្នកចាប់អារម្មណ៍ធ្វើការដើម្បីធានាឲ្យសហគមន៍ដែលងាយរងគ្រោះ អាចចូលទៅទទួលសេវាសុខាភិបាលបានដែរឬទេ? បើអ្នកចាប់អារម្មណ៍ អ្នកអាចចូលរួមជាមួយយើង!

អង្គការមិត្តសំឡាញ់ គឺជាអង្គការក្នុងស្រុកឈានមុខគេមួយដែលធ្វើការជាមួយកុមារ យុវវ័យ គ្រួសារ ដែលបាត់បងឱកាស និងសហគមន៍របស់ពួកគេ ដើម្បីជួយពួកគេឲ្យក្លាយទៅជាពលរដ្ឋឯករាជ្យ និងមានផលិទ្ធភាពសម្រាប់ប្រទេសរបស់ពួកគេ។

ក្រុមពហុជំនាញរបស់យើង រួមមានគ្រូបង្រៀន បុគ្គលិកសង្គម មន្ត្រីដាក់ការងារ អ្នកថែរក្សាកុមារ បាននឹងកំពុងធ្វើការជាមួយគ្នា ដើម្បីធានាថាយើងសង្គ្រោះជីវិត និងកសាងអនាគតឲ្យកុមារ យុវវ័យ គ្រួសារ និងសហគមន៍របស់ពួកគេ។

**តើអ្នកនឹងត្រូវធ្វើអ្វី?**
ក្នុងតួនាទី ជាគ្រូពេទ្យ អ្នកនឹងក្លាយជាផ្នែកមួយនៃក្រុមការងារនេះ ដើម្បីធានាថាគ្រប់គ្នាទទួលបាននូវសេវាវេជ្ជសាស្ត្រ ដែលមានគុណភាពខ្ពស់ ទាំងនៅក្នុងសហគមន៍ និងនៅក្នុងមណ្ឌលរបស់យើងផងដែរ។

អ្នកនឹងធ្វើការនៅក្នុងមណ្ឌលណាមួយនៃអង្គការមិត្តសំឡាញ់ នៅក្នុងរាជធានីភ្នំពេញ នឹងត្រូវចល័តទៅតាមតំបន់នានា ដែលត្រូវការសេវាសុខភាព។

**តួនាទី នឹងការទទួលខុសត្រូវរបស់គ្រូពេទ្យមានដូចខាងក្រោម៖**

- ផ្តល់ការថែទាំសុខភាពជាមូលដ្ឋាន ដល់កុមារ យុវវ័យ និងគ្រួសាររបស់ពួកគេ នៅតាមផ្លូវ និងក្នុងសហគមន៍
- សម្របសម្រួលក្នុងការបញ្ជូនកុមារ យុវវ័យ និងគ្រួសារ ទៅកាន់សេវាដៃគូ និងធានានូវការត្រួតពិនិត្យយ៉ាងទៀងទាត់នៃសេវាកម្មរបស់ពួកគេ
- ផ្តល់ការបណ្តុះបណ្តាល និងការគាំទ្រ ដល់ក្រុម ដើម្បីផ្តល់ការថែទាំសុខភាពជាមូលដ្ឋាន ដល់កុមារ និងយុវជននិងគ្រួសាររបស់ពួកគេ
- ផ្តល់សេវាកាត់បន្ថយគ្រោះថ្នាក់ដល់អ្នកប្រើគ្រឿងញៀន
- ត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពអនាម័យនៃតំបន់ការងារ និងមជ្ឈមណ្ឌល
- ទុកដាក់ និងថែរក្សាឲ្យបានត្រឹមត្រូវនូវសម្ភារៈវេជ្ជសាស្ត្រ (ថ្នាំពេទ្យ ស្រោមអនាម័យ ស៊ីរ៉ាំង ម្ជុល)។

**លក្ខខណ្ឌជ្រើសរើស:**

- អ្នកគឺជាបុគ្គលស្វាហាប់ អ្នកធ្វើការងារជាក្រុមនិងមានភាពឯករាជ្យ និងចូលចិត្តធ្វើការជាមួយកុមារនិងយុវវ័យ
- អ្នកមានបទពិសោធន៍ច្រើនក្នុងការផ្តល់សេវាថែទាំ
- អ្នកមានឥរិយាបថរួសរាយរាក់ទាក់ ហើយអ្នកចូលចិត្តធ្វើការជាមួយអ្នកជំងឺ
- អ្នកមានចំនេះដឹងអំពីជំងឺកាមរោគ អេដស៍ សុខភាពបន្តពូជ និងអាហារូបត្ថម្ភ
- មានជំនាញគិលានុបដ្ឋ ឬសញ្ញាប័ត្រពាក់ព័ន្ធ

បេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ សូមផ្ញើរនូវប្រវត្តិរូបសង្ខេប (CV និង Cover Letter) មកទីស្នាក់ការអង្គការមិត្តសំឡាញ់ អាសយដ្ឋានផ្ទះលេខ២១៥ ផ្លូវលេខ១៣ ខាងជើងសារៈមន្ទីរជាតិ ឬ E-mail: hr@mithsamlanh.org ដោយបញ្ជាក់ពីតួនាទី និងប្រាក់បៀវត្សរ៍ពឹងទុក។ ព័ត៌មានបន្ថែមអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទ ០២៣ ២២០ ៥៩៦។

អង្គការមិត្តសំឡាញ់ ផ្តល់នូវភាពយុត្តិធម៌ដល់អ្នកដាក់ពាក្យទាំងអស់។ បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវទំនាក់ទំនងដើម្បីធ្វើការសម្ភាសន៍។

**អង្គការមិត្តសំឡាញ់គោរពតាមគោលការណ៍ការពារកុមារ។**
**ទទួលពាក្យចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២។**